មាត្រា ៩ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និង សេដ្ឋកិច្ច អនុរដ្ឋលេខាធិការ អាកាសចរណ៍ស៊ីវិល និង រដ្ឋមន្ត្រី រដ្ឋលេខាធិការ និង ស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវទទួលការៈរៀងខ្លួនចាត់ការអោយបានសំរេចតាមអនុក្រឹត្យនេះ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និងត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * * *

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៧៥ អនក្រ
## ស្តីពីការធ្វើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤
## របស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពី ការបែងចែកឥណទាន តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤

-តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**សំរេច**

មាត្រា ១ : អនុញ្ញាតអោយធ្វើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ ចំនួន ៣៨៦.០០០.០០០រ០០" បីរយប៉ែតសិបប្រាំមួយលានរៀលគត់ " ពីជំពូក ៣០ : អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច

បញ្ចូលទៅក្នុងជំពូក ៣១ : អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច វប្បធម៌ សំរាប់ចំណាយទិញប្រេងឥន្ធនៈ ជួសជុលម៉ាស៊ីនបូមទឹក ស្តារប្រឡាយ និង ទំនប់ ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ ។

មាត្រា ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * * *

# II ការងារបណ្តាក្រសួង

## ១- ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស លេខ ១៧០៧ ឧក.ប្រក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៤

ប្រការ ១ : អនុញ្ញាតអោយ លោក ងួរ កុកគី ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៣៩៩៩៩១ ព.ស ចុះថ្ងៃទី ០៦-៥-៨៨ អាស័យ